ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៣ សហវ

ថ្ងៃ ៧ ៨ ១ ១៤ ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០២០

# សារាចរណែនាំ
## ស្តីពី
## ការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយលើកទី ២ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០

- យោងព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- យោងព្រះរាជក្រមលេខនស/រកម/១២១៩/០២៥ ចុះថ្ងៃ សុក្រ ០៩រោច ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៩ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- យោងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- យោងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- យោងអនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃ សុក្រ ០២កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- យោងអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃ សុក្រ ០២កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- យោងប្រកាសលេខ ១៤២៩ សហវ.ប្រក ចុះថ្ងៃ ចន្ទ ០៥កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០

- យោងសារាចរណែនាំលេខ ០០១ សហវ-អថ ចុះថ្ងៃ សុក្រ ១៣កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយសម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- យោងការសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០២០ ។

ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចសកល និងស្ថានភាពម៉ាក្រូសេដ្ឋកិច្ច កំពុងវិវត្តធាប់រហ័ស និងចល័តយ៉ាងលឿនពិបាកប៉ាន់ប្រមាណឱ្យបានច្បាស់លាស់ ដោយសារផលប៉ះពាល់ធ្ងន់ធ្ងរនៃការរីករាលដាលនៃជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលបានធ្វើការវាយតម្លៃឡើងវិញអំពីផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ មកលើក្របខណ្ឌច្បាប់ថវិកាជាតិពេញ ១ ឆ្នាំ ២០២០ និងបានសម្រេចបង្វែរទិសនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពី "**ថវិកាវិត្ថារកម្ម**" (stimulus budget) ដើម្បីលើកកម្ពស់កំណើន ទៅជា "**ថវិកាតបះកម្ម ឬ រឹតបន្តឹងចំណាយ**" (austerity budget) កម្រិតខ្ពស់មួយ ដើម្បីបង្វែរថវិកាឆ្ពោះទៅដោះស្រាយការងារអាទិភាពចំពោះមុខចំនួន ៤ រួមមាន ៖ *(១)- ប្រយុទ្ធប្រឆាំងទៅនឹងជំងឺកូវីដ-១៩, (២)- រក្សាលំនឹងជីវភាពប្រជាជនក្នុងកម្រិតអប្បបរមាមួយ (មិនឱ្យអត់បាយ) ជាពិសេសសម្រាប់ប្រជាជនក្រីក្រ និងអ្នកបាត់បង់ការងារ, (៣)- ខិតខំជួយឱ្យអស់លទ្ធភាពដើម្បីឱ្យធុរកិច្ច និង អាជីវកម្មអាចរស់បាន និង រក្សាការងារ ជាពិសេស រក្សា និង ជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និង (៤)-រក្សាឱ្យបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និង ស្ថិរភាពសង្គម*។

ក្នុងន័យនេះ បន្ថែមលើការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយលើកទី ១ តាមរយៈការអនុវត្តសារាចរណែនាំលេខ ០០១ សហវ-អថ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០២០, និង ក្នុងស្មារតីសាមគ្គីភាពជាតិ និងការចែករំលែកបន្ទុកដ៏ធ្ងន់របស់ជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដ៏កាចសាហាវនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន, គ្រឹះស្ថានសាធារណៈរដ្ឋបាល, មន្ទីរជំនាញរាជធានី ខេត្ត និង រដ្ឋបាលរាជធានី ខេត្ត ធ្វើវិចារណកម្ម និងពង្រឹងប្រសិទ្ធភាពចំណាយលើកទី ២ ដោយកាត់សន្សំចំណាយបន្ថែមឱ្យគ្រប់ ៥០% សម្រាប់ការអនុវត្តចំណាយថវិកាឆ្នាំ ២០២០ លើមុខចំណាយមួយចំនួនដែលបានកំណត់ ដូចខាងក្រោម៖

១. <u>ក្រសួង ស្ថាប័ន រដ្ឋបាលកណ្តាល</u>

- កាត់សន្សំចំណាយប្រេងឥន្ធនៈ និងប្រេងរំអិល ៣៧% បន្ថែមពីលើការកាត់សន្សំលើកទី ១ ចំនួន ១៣% ចំពោះគ្រប់ក្រសួង ស្ថាប័នទាំងអស់ ដោយលើកលែងការកាត់បន្ថែមនេះចំពោះក្រសួងសុខាភិបាល, ក្រសួងការពារជាតិ, ក្រសួងមហាផ្ទៃ (ផ្នែកសន្តិសុខសាធារណៈ)
- កាត់សន្សំចំណាយ ៣៥% បន្ថែមលើការកាត់សន្សំលើកទី ១ ចំនួន ១៥% លើមុខសញ្ញាចំណាយ

រួមមានៈ សម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា ព្រមទាំងសម្ភារៈការិយាល័យ ចំពោះគ្រប់ក្រសួង ស្ថាប័ន ទាំងអស់

- កាត់សន្សំចំណាយ ៥០% លើមុខសញ្ញា រួមមានៈ សម្ភារៈ និងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា, សង្ហារិម និង សម្ភារប្រើប្រាស់ ចំពោះគ្រប់ក្រសួង ស្ថាប័នទាំងអស់
- កាត់សន្សំចំណាយឯកសណ្ឋាន ៥០% ដោយលើកលែងចំពោះ ក្រសួងសុខាភិបាល, ក្រសួងការពារជាតិ, ក្រសួងមហាផ្ទៃ (ផ្នែកសន្តិសុខសាធារណៈ) និង ក្រសួងមហាផ្ទៃ (ផ្នែករដ្ឋបាលទូទៅលើឯកសណ្ឋានមន្ត្រីពន្ធនាគារ និង ពិរុទ្ធជន)
- កាត់សន្សំចំណាយ ៥០% លើមុខសញ្ញា រួមមានៈ សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស, ប្រជុំ សិក្ខាសាលា និងសន្និសីទ, និង ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ ចំពោះគ្រប់ក្រសួង ស្ថាប័នទាំងអស់
- កាត់សន្សំចំណាយសម្រាប់ការតាំងពិព័រណ៍នៅក្នុង និងក្រៅប្រទេស ៥០% ចំពោះគ្រប់ក្រសួង ស្ថាប័នទាំងអស់ ។ *ចំពោះការចូលរួមពិព័រណ៌អន្តរជាតិ នៅទីក្រុងឌុយបៃ គឺត្រូវបានរាជរដ្ឋាភិបាលសម្រេចលុបតែម្តង ។*
- កាត់សន្សំចំណាយ ៥០% លើមុខសញ្ញា រួមមានដូចជាៈ សោហ៊ុយទទួលភ្ញៀវជាតិ, សោហ៊ុយទទួលភ្ញៀវបរទេស ចំពោះគ្រប់ក្រសួង ស្ថាប័នទាំងអស់
- កាត់សន្សំចំណាយសម្រាប់ចំណាយលើវត្ថុអនុស្សាវរីយ៍នៅក្នុង និងក្រៅប្រទេស ៥០% ចំពោះគ្រប់ក្រសួង ស្ថាប័នទាំងអស់
- កាត់សន្សំចំណាយបេសកកម្មក្នុងប្រទេស ៥០% ចំពោះក្រសួង ស្ថាប័នទាំងអស់ ដោយលើកលែងចំពោះក្រសួងសុខាភិបាល, ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ(ផ្នែកសន្តិសុខសាធារណៈ)។

ដោយឡែក *ការសន្សំចំណាយខាងលើនេះ ត្រូវបានលើកលែងជូនស្ថានបេសកកម្មកម្ពុជានៅបរទេសទាំងអស់លើគ្រប់មុខចំណាយសម្រាប់ដំណើរការទូទៅ រួមទាំង ការទិញយានយន្ត ដើម្បីជួយពង្រឹងប្រសិទ្ធភាពនៃការបំពេញការងារការទូតរបស់កម្ពុជា ។*

២. <u>គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលទទួលឧបត្ថម្ភធន ១០០% ពីថវិកាជាតិ</u>

- កាត់សន្សំចំណាយប្រេងឥន្ធនៈ និងប្រេងរំអិល ៣៧% បន្ថែមពីលើការកាត់សន្សំលើកទី ១ ចំនួន ១៣%
- កាត់សន្សំចំណាយ ៣៥% បន្ថែមពីលើការកាត់សន្សំលើកទី ១ ចំនួន ១៥% លើមុខសញ្ញា រួមមានដូចជា ៖ សម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា និងសម្ភារការិយាល័យ
- កាត់សន្សំចំណាយ ៥០% លើមុខសញ្ញាចំណាយ រួមមានដូចជាៈ សម្ភារ និងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា, សង្ហារិម, សម្ភារប្រើប្រាស់, ឯកសណ្ឋាន, សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស, សោហ៊ុយទទួលភ្ញៀវជាតិ, សោហ៊ុយទទួលភ្ញៀវបរទេស, ប្រជុំ សិក្ខាសាលា និងសន្និសីទ,

ចំណាយសម្រាប់អនុស្សាវរីយ៍នៅក្នុង និងក្រៅប្រទេស, ចំណាយសម្រាប់ការតាំងពិព័រណ៍នៅក្នុង និងក្រៅប្រទេស, ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ និង បេសកកម្មក្នុងប្រទេស ។

ដោយឡែក គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលទទួលបានឧបត្ថម្ភធនពីថវិកាជាតិមួយផ្នែកសម្រាប់បំពេញតុល្យភាពចំណូល-ចំណាយប្រចាំឆ្នាំ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ថវិកាក្នុងកម្រិតតុល្យភាពរបស់ខ្លួន ប៉ុន្តែនឹងមិនមានការបន្ថែមឥណទានថវិកាជូនទេ ក្នុងករណីចំណូលផ្ទាល់មានការថយចុះ ។

**៣. <u>អង្គភាពជាក្រុមប្រឹក្សា អាជ្ញាធរ និងគណៈកម្មាធិការរបស់រាជរដ្ឋាភិបាល</u>**

ចំពោះអង្គភាពដែលជាក្រុមប្រឹក្សា, អាជ្ញាធរ និង គណៈកម្មាធិការនានារបស់រាជរដ្ឋាភិបាល ដែលមានកញ្ចប់ថវិកាស្ថិតនៅក្រោមក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យប្រសិទ្ធភាពចំណាយ ដើម្បីសន្សំ និង បង្កកមុខចំណាយជាក់ស្តែងទៅតាមលំនាំនៃគោលការណ៍រួមខាងលើ នៅពេលអង្គភាពនីមួយៗស្នើសុំចំណាយមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**៤. <u>ចំណាយចរន្តក្នុងការអនុវត្តគម្រោង</u>**

កាត់សន្សំចំណាយ ២០% នៃកញ្ចប់ចំណាយចរន្តសរុបសម្រាប់ការអនុវត្តគម្រោងនានា ។

**៥. <u>មន្ទីរជំនាញរាជធានី ខេត្ត</u>**

បន្ថែមលើការព្យួរការអនុវត្តរាល់ការទិញរថយន្តសម្រាប់បម្រើការងាររដ្ឋបាលរបស់មន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ថវិការបស់មន្ទីរជំនាញរាជធានី ខេត្តនីមួយៗ ត្រូវបានកាត់សន្សំចំណាយ ២៥% លើមុខសញ្ញា រួមមាន៖ សម្ភារការិយាល័យ, សម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា, ប្រេងឥន្ធនៈ និង ប្រេងរំអិល (លើកលែងតែមន្ទីរសុខាភិបាល), ប្រជុំ សិក្ខាសាលា និងសន្និសីទ និង សោហ៊ុយបេសកកម្មក្នុងប្រទេស ។

**៦. <u>រដ្ឋបាលរាជធានី ខេត្ត</u>**

ដើម្បីរួមចំណែកចែករំលែកការលំបាកដ៏ធ្ងន់ជាមួយថ្នាក់ជាតិ, រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវយកចិត្តទុកដាក់ខិតខំកៀរគរចំណូលក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ។ ចំពោះផ្នែកចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមគោលការណ៍ ដូចខាងក្រោម ៖

- កាត់បន្ថយទាំងចំណាយចរន្ត និង ចំណាយវិនិយោគ ដោយធ្វើការតម្រឹមទៅតាមការធ្លាក់ចុះនៃចំណូលចរន្តរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ ទាំងចំណូលសារពើពន្ធ និងទាំងពីចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ
- ផ្អាកការផ្ទេរសាច់ប្រាក់មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ សម្រាប់ត្រីមាសទី ២ និង ត្រីមាសបន្តបន្ទាប់ រហូតដល់មានគោលការណ៍អនុញ្ញាតឡើងវិញ ។

ក្នុងការអនុវត្តនូវវិធានការដែលបានដាក់ចេញខាងលើ គ្រប់ក្រសួង ស្ថាប័នត្រូវកែតម្រូវទំហំឥណទានសរុប រួមទាំង **តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន** របស់ខ្លួន ទៅតាមទំហំនៃមុខសញ្ញាចំណាយទាំងអស់ដែលបានកាត់សន្សំខាងលើ និងទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពពាក់ព័ន្ធ ។

គ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្ត និងអង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- អគ្គលេខាធិការដ្ឋានក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី ខេត្ត
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ